ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តព្រៃវែង
លេខ: ១៥០/២១ ស.ណន

# សេចក្តីណែនាំ
## ស្តីពី
## ការផ្អាកលក់គ្រឿងស្រវឹងគ្រប់ប្រភេទ និងការផ្អាកការជួបជុំ
## រយៈពេល ១៤ថ្ងៃ ចាប់ពីថ្ងៃទី ១៥ ខែមេសា ដល់ថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០២១
## នៅក្នុងភូមិសាស្ត្រខេត្តព្រៃវែង

ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ **"សហគមន៍ ២០ កុម្ភៈ"** និងក្នុងគោលបំណងការពារអាយុជីវិតរបស់ប្រជាពលរដ្ឋ សុខភាពសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ **រដ្ឋបាលខេត្តព្រៃវែង** សូមធ្វើការណែនាំនូវវិធានការចាំបាច់មួយចំនួន ដូចខាងក្រោម៖

១. ផ្អាកការលក់ដូរគ្រឿងស្រវឹងគ្រប់ប្រភេទ (ស្រាបៀរ-ស្រាគ្រប់ប្រភេទ) នៅក្នុងភូមិសាស្ត្រខេត្តព្រៃវែង។

២. គ្រប់ផ្សាររដ្ឋ ផ្សារឯកជន ផ្សារម៉ាត ភោជនីយដ្ឋាន អាហារដ្ឋាន តូបអាហារ ហាងកាហ្វេ ហាងភេសជ្ជៈ ទីតាំងអាជីវកម្មផ្នែកអាហារ-ភេសជ្ជៈ និងដេប៉ូចែកចាយគ្រឿងស្រវឹងនៅក្នុងភូមិសាស្ត្រខេត្ត ត្រូវផ្អាកជាបណ្តោះអាសន្ននូវការលក់ដូរគ្រឿងស្រវឹងគ្រប់ប្រភេទ។

៣. ប្រជាពលរដ្ឋត្រូវនៅតាមផ្ទះរៀងៗខ្លួនក្នុងគ្រួសារនីមួយៗ។ ចំពោះការជួបជុំប្រមូលផ្តុំគ្នាច្រើន ពីផ្ទះមួយ ទៅផ្ទះមួយ ការពិសារគ្រឿងស្រវឹង និងការចាក់បាសរ៉ាក់ម្សាន្តតាមផ្ទះត្រូវហាមឃាត់ជាដាច់ខាត។

៤. ស្នងការដ្ឋាននគរបាលខេត្ត បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត មន្ទីរ-អង្គភាពពាក់ព័ន្ធ និងរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ត្រូវធ្វើការណែនាំ ហាមឃាត់ និងទប់ស្កាត់ការជួបជុំ លក់ដូរ និងការពិសារគ្រឿងស្រវឹងគ្រប់ប្រភេទ។

៥. គ្រប់ទីតាំងអាហារដ្ឋាន ភោជនីយដ្ឋាន ផ្សារម៉ាត អាជីវករ អ្នកលក់ដូរ ចែកចាយគ្រឿងស្រវឹងគ្រប់ប្រភេទ និងបងប្អូនប្រជាពលរដ្ឋដែលមិនអនុវត្តតាមការណែនាំខាងលើ ត្រូវអនុវត្តវិធានការរដ្ឋបាល និងវិធានការច្បាប់ដោយគ្មានការលើកលែងឡើយ។

ទទួលបានសេចក្តីណែនាំនេះ **ស្នងការដ្ឋាននគរបាលខេត្ត បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ម្ចាស់អាជីវកម្មគ្រប់ប្រភេទ អាជីវករ និងបងប្អូនប្រជាពលរដ្ឋ** ត្រូវអនុវត្តសេចក្តីណែនាំខាងលើ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ ព្រហ ៤ កើត ខែ ចេត្រ ឆ្នាំឆ្លូវ ទោស័ក ព.ស.២៥៦៤
ព្រៃវែង ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ២០២១
**អភិបាលខេត្ត**

ជា សុមេធី

**កន្លែងផ្ញើ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសុខាភិបាល
- ក្រុមប្រឹក្សាខេត្ត
  "ដើម្បីគោរពជូនជ្រាប"
- រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់
  "ដើម្បីអនុវត្ត"
- មន្ទីរព័ត៌មានខេត្ត "ដើម្បីផ្សព្វផ្សាយ"
- ឯកសារ កាលប្បវត្តិ

ភូមិលេខ១ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង
Village1,Sangkat Kampong Leav,Krong Prey Veng,Prey Veng Province
ទូរស័ព្ទ និងទូរសារ : (+៨៥៥) ៤៣ ២១៨ ៨៨៨,អ៊ីម៉ែល: preyvengprovince@gmail.com.kh
Phone and Fax: (+855) 43 218 888, Email: preyvengprovince@gmail.com.kh